## នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2013, 14:14
CMS/CFO: Ly Bunloung

---

## សារណាតបរួមរបស់សហមេធាវីនាំមុខ ទៅនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តី ស្តីពីភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

**<u>នៅចំពោះមុខ៖</u>**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**<u>ផ្ញើជូន៖</u>**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

យុង ផានិត

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

គង់ ផល្លៈ

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Jeanne SULZER
Philippine SUTZ
Beini YE

ជា លាង
Andrew T. CAYLEY

យ៉េត ចរិយា
William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

អៀង សារី

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ
Victor KOPPE

អាង ឧត្តម
Michael G. KARNAVAS

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGES

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

# I. សេចក្ដីផ្ដើម

1. នៅក្នុងឯកសារនេះ ដើមបណ្ដឹងរដ្ឋប្បវេណីសូមឆ្លើយតបទៅនឹងសេចក្ដីជំទាស់ដែលត្រូវបានលើកឡើងដោយមេធាវីការពារក្ដី ខៀវ សំផន និង នួន ជា ចំពោះការទទួលយកកំណត់ហេតុស្ដាប់ចម្លើយ ដែលមាននៅក្នុងគំរូដែលជាតំណាងឲ្យកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[1]។

2. ដូចដែលសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់រួចហើយគឺថា[2] ទឡ្ហីករណ៍ និងសេចក្ដីជំទាស់ដែលត្រូវបានមេធាវីការពារក្ដីលើកឡើង ភាគច្រើនប៉ុនប៉ងក្នុងការលើកអំណះអំណាងជាថ្មី និងពិនិត្យមើលឡើងវិញនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ដែលបានបង្កើតក្របខណ្ឌគតិយុត្តសម្រាប់ការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់[3]។ ទឡ្ហីករណ៍នានាតបទៅនឹងកិច្ចខិតខំទាំងនេះ ត្រូវបានវិភាគយ៉ាងល្អិតល្អន់នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងហេតុដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីសូមដាក់បញ្ចូលភាគច្រើននៃទឡ្ហីករណ៍ទាំងនេះ ទៅក្នុងសារណានេះ។ ដើម្បីផលប្រយោជន៍នៃប្រសិទ្ធិភាព ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីកំហិតត្រឹមចំណុចជាក់លាក់មួយចំនួនតូចស្ដីពីច្បាប់ជាធរមាន និងបន្ទាប់មក ផ្ដោតលើលក្ខណៈ និងភាពគ្រប់គ្រាន់នៃសេចក្ដីជំទាស់ជាទូទៅ ដែលមេធាវីការពារក្ដីបានលើក ព្រមទាំងសេចក្ដីជំទាស់ជាក់លាក់ដែលត្រូវបានលើកឡើងជំទាស់ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយនីមួយៗដែលដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំដាក់ជាភស្តុតាង។

---

[1] ឧបសម្ព័ន្ធ ១ សម្គាត់ ៖ ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនបានផ្ដល់សក្ខីកម្មផ្ទាល់មាត់ ឯកសារ **E223/2/7.2** ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១២ (ដែលចាប់ពីពេលនេះទៅហៅថា "តារាងខែ មីនា")។

[2] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដីចំពោះការទទួលយកកំណត់ហេតុសាក្សី ពាក្យបណ្ដឹង និងប្រតិចារឹក ឯកសារ **E277/1** កថាខណ្ឌ២ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ដែលចាប់ពីពេលនេះទៅហៅថា "ចម្លើយតបរបស់សហព្រះរាជអាជ្ញា"។

[3] សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (ដែលចាប់ពីពេលនេះទៅហៅថា "សេចក្ដីសម្រេចទាក់ទិននឹងកំណត់ហេតុស្ដាប់ចម្លើយ"។

3. ដោយពិចារណាទៅលើអង្គហេតុដែលថា អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានសម្រេចថាខ្លួននឹងមិនសម្រេចលើកទឡ្ហីករណ៍ផ្ទាល់មាត់ស្តីពីភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ កាលពីថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់ចម្លើយតបរបស់ខ្លួនតែមួយភាសា ដើម្បីតបទៅនឹងការជំទាស់របស់មេធាវីការពារក្តីទៅលើចំណុចនេះ មិនឱ្យហួសពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ ដោយឯកសារបកប្រែនឹងដាក់ពេលក្រោយ[4]។ អាស្រ័យហេតុនេះ ចម្លើយតបនេះ ត្រូវបានដាក់ទាន់ពេលវេលា។

## II. ប្រវត្តិនីតិវិធី

4. កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយ ដែលតាមរយៈសេចក្តីសម្រេចនេះ អង្គជំនុំជម្រះបានណែនាំភាគីនានាដែលស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកនៅចំពោះមុខអង្គជំនុំជម្រះ ឱ្យពិនិត្យឡើងវិញនូវឯកសារដែលមាននៅក្នុងបញ្ជីពាក់ព័ន្ធរបស់ខ្លួន ដើម្បីឱ្យស្របជាមួយនឹងលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងសេចក្តីសម្រេច និងបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគោលបំណងនៃភស្តុតាងរបស់ឯកសារនីមួយៗ ឬប្រភេទនៃឯកសារ និងពិចារណាអំពីការកំណត់ចំនួនឯកសារដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ សម្រាប់ “ជាគំរូដែលតំណាង”ឱ្យឯកសារ[5]។

5. កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការឆ្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយរបស់អង្គជំនុំជម្រះ និងសេចក្តីបង្គាប់បន្តបន្ទាប់របស់អង្គជំនុំជម្រះផ្ញើជូនភាគីដើម្បីឱ្យបង្ហាញកំណត់ហេតុស្តាប់ចម្លើយទាំងនោះ ពីក្នុងបញ្ជីឯកសាររបស់ពួកគាត់ ដែលបានដាក់កាលពីខែ មេសា ឆ្នាំ ២០១១ ដែលបានស្នើសុំពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងដំណាក់កាលទី ២[6]។

---

[4] អ៊ីមែលរបស់ Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី “ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីកំណត់ហេតុស្តាប់ចម្លើយ និងសេចក្តីសន្និដ្ឋានបញ្ចប់ (២០០៨)” ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣។

[5] សេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ៣៥។

[6] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈ E208/3 និងសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង

6. កាលពីថ្ងៃទី 0៤ ខែ មីនា ឆ្នាំ ២០១៣ ដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សារណា និងតារាងដែលមានឯកសារចំនួន ៥៦៦ ដែលមានកំណត់ហេតុស្ដាប់ចម្លើយសរុបទាំងអស់៥២0 ដែលដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យដាក់ជាឯកសារភ័ស្ដុតាង ជំនួសឱ្យការផ្ដល់សក្ខីកម្មផ្ទាល់មាត់របស់ពួកគាត់[7]។ ឯកសារទាំងនេះ បង្កើតបានជាគំរូដែលតំណាងឱ្យកំណត់ហេតុស្ដាប់ចម្លើយ ដែលអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យភាគីនានាផ្ដល់ជូន[8]។ គំរូនេះបានដាក់បញ្ចូលចំនួនឯកសារសរុប ដែលត្រូវបានកាត់បន្ថយយ៉ាងច្រើន ដែលត្រូវបានស្នើសុំឱ្យដាក់បញ្ចូលជាភ័ស្ដុតាង បើប្រៀបធៀបទៅនឹងសំណើសុំពីមុនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[9]។ ដើម្បីឆ្លើយតបបន្ថែមទៅនឹងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ និងឯកសារនីមួយៗដែលមាននៅក្នុងគំរូនេះ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ចំណុចពាក់ព័ន្ធនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងគោលបំណងនៃភ័ស្ដុតាង ដោយផ្អែកលើ

ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងE96/7 ដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធសម្ងាត់ទី១ និងទី២ ឯកសារ E208/4 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ (ដែលចាប់ពីពេលនេះទៅហៅថា "សារណាតបទាក់ទិននឹងកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី"។

[7] សូមមើល ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការស្នើសុំឱ្យទទួលយកភ័ស្ដុតាងកំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងឯកសារផ្សេងទៀត (ភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ និងសម្ងាត់បំផុត) ឯកសារ E223/2/7 ថ្ងៃទី 0៤ ខែ មីនា ឆ្នាំ ២០១២ (ដែលចាប់ពីពេលនេះទៅហៅថា "សារណាថ្ងៃទី 0៤ ខែ មីនា") និងតារាង ថ្ងៃទី 0៤ ខែ មីនា។ ចំនួនឯកសារសរុប មានចំនួនច្រើនជាងចំនួនសរុបនៃកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ពីព្រោះដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ចម្លើយចំនួន៤៦ ដែលដើមបណ្ដឹងរដ្ឋប្បវេណីដឹងថាជាការបកប្រែចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាភាសាបារាំង នៅក្នុងបញ្ជីដែលមាននៅក្នុងលេខឯកសារផ្សេងគ្នា។ *សូមមើលដូចខាងក្រោម* នៅត្រង់កថាខណ្ឌ ៤១-៤៣ សម្រាប់ការពិភាក្សាបន្ថែមទៅលើបញ្ហានេះ។

[8] សេចក្ដីសម្រេចទាក់ទិននឹងកំណត់ហេតុស្ដាប់ចម្លើយ កថាខណ្ឌ៣៥។

[9] *សូមមើល* ឧបសម្ព័ន្ធ ៧(ក)(iii)ដែលត្រូវបានកែសម្រួល៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារE109/2.2 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ *សូមមើលផងដែរ* បញ្ជីឈ្មោះដែលត្រូវបានកែសម្រួលរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីឯកសារនិងវត្ថុតាង ដែលពាក់ព័ន្ធទៅនឹងចំណុចអង្គហេតុទាំងបួនដែលត្រូវធ្វើសវនាការដំណាក់កាលដំបូង ឯកសារ E109/2 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ១២ (រៀបរាប់ថា ខ្លឹមសារទាំងស្រុងនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានរួមបញ្ចូលឯកសារឧបសម្ព័ន្ធណាមួយដើម្បីបន្ថែមទៅលើឯកសារលេខ D22 ត្រូវបានបញ្ចូលនៅក្នុងបញ្ជីនេះ)។ ផ្អែកតាមការប៉ាន់ស្មានដែលរក្សាទុកដែលថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ មានតែឯកសារដាច់ដោយឡែកចំនួនបីប៉ុណ្ណោះនៅក្នុងសំណុំរឿង ដូចនេះគំរូដែលជាតំណាងឱ្យឯកសារនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង តំណាងឱ្យការកាត់បន្ថយ ២.២00% នៃចំនួនឯកសារនានាដែលបានស្នើសុំ។

មូលដ្ឋាននៃចំណុចពាក់ព័ន្ធទាំងនេះ ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យទទួលយកឯកសារនានាដែលមាននៅក្នុងគំរូរបស់ពួកគាត់។

7. កាលពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ មេធាវីការពារក្តី ខៀវ សំផន បានដាក់សារណាអនុលោមតាមវិធាន៩២ ស្តីពីបទដ្ឋានគតិយុត្តដែលអាចអនុវត្តបានចំពោះការទទួលយកកំណត់ហេតុស្តាប់ចម្លើយ[10] ដែលតាមរយៈសារណានេះ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តនូវ "កំហុសអង្គច្បាប់" នៅក្នុងការកំណត់ក្របខណ្ឌគតិយុត្តិស្តីពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងមេធាវីការពារក្តីបានលើកឡើងម្តងហើយម្តងទៀតអំពីទឡ្ហីករណ៍ផ្លូវច្បាប់ដូចគ្នា ដែលមាននៅក្នុងសារណារបស់ខ្លួន មុនពេលចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[11]។ មេធាវីការពារក្តីក៏បានលើកឡើងការជំទាស់ជាទូទៅជាច្រើនទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

8. កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ មេធាវីការពារក្តី ខៀវ សំផន បានដាក់ការជំទាស់របស់ខ្លួនទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់។ សារណាបានលើកឡើងសាជាថ្មី និងលើកឡើងបន្ថែមលើការជំទាស់ដែលមាននៅក្នុងសារណា អនុលោមតាមវិធាន ៩២ ពីមុនរបស់មេធាវីការពារក្តី។ នៅក្នុងឧបសម្ព័ន្ធនៃសារណានេះ មេធាវីការពារក្តី ខៀវ សំផន បានពិនិត្យមើលឡើងវិញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤៩០ ក្នុងចំណោមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីពិសេសចំនួន ៥២០ ដែលធ្វើការជំទាស់ទៅនឹងឯកសារជាក់លាក់ទាំងអស់លើកលែងតែឯកសារចំនួន ៤ ក្នុងចំណោមឯកសារ៤៩០ ប៉ុណ្ណោះ។ អាស្រ័យហេតុនេះ មេធាវីការពារក្តី ខៀវ សំផន ខកខានមិនបានលើកឡើងការជំទាស់ដាច់ដោយឡែកទៅនឹងកំណត់ហេតុស្តាប់ចម្លើយចំនួន៣៤ ដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ការជំទាស់ទៅនឹងឯកសារជាក់លាក់របស់មេធាវីការពារក្តី ឋិតនៅក្រោមប្រភេទសំខាន់ចំនួនបួន៖ វិសាលភាព ទង្វើ និងការប្រព្រឹត្ត ចេតនារើសអើង និងការប្រមូលដោយលំអៀង ។

---

[10] សេចក្តីសន្និដ្ឋានអនុលោមតាមវិធាន ៩២ អំពីច្បាប់អនុវត្តលើការទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារE277 ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ (ដែលចាប់ពីពេលនេះតទៅហៅថា "សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន អនុលោមតាមវិធាន៩២")។

[11] សេចក្តីសង្កេតតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ E96/4 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (ដែលចាប់ពីពេលនេះតទៅហៅថា "ការជំទាស់បឋមរបស់ ខៀវ សំផន")។

9. នៅខែ វិច្ឆិកា ឆ្នាំ ២០១២ និងខែ មេសា ឆ្នាំ ២០១៣ មេធាវីការពារក្តី នួន ជា បានដាក់សេចក្តីជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់[12]។ នៅពេលក្រោយមក មេធាវីការពារក្តីបានលើកឡើងសាជាថ្មីអំពីទឡ្ហីករណ៍ដើមជាច្រើនរបស់ខ្លួន ដែលទាក់ទិននឹងក្របខណ្ឌគតិយុត្ត សម្រាប់ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ដែលក្របខណ្ឌគតិយុត្តនេះ មិនត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួននោះទេ ប៉ុន្តែត្រូវបានលើកទឡ្ហីករណ៍មុនសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ[13]។ នៅក្នុងការដាក់ឯកសារក្រោយមកទៀត មេធាវីការពារក្តីក៏បានលើកឡើងការជំទាស់ជាទូទៅមួយចំនួនទៅលើភាពពាក់ព័ន្ធ ភាពអាចជឿទុកចិត្ត និងយថាភាពនៃឯកសារ[14] ប៉ុន្តែការជំទាស់ជាសំខាន់ ឋិតនៅក្រោមប្រភេទចម្បងចំនួនប្រាំ៖ វិសាលភាព អំពើនិងការប្រព្រឹត្តិរបស់ជនជាប់ចោទ និងរចនាសម្ព័ន្ធ[15]។

10. កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ បីថ្ងៃបន្ទាប់ពីការផុតកំណត់កាលបរិច្ឆេទដាក់ឯកសាររបស់អង្គជំនុំជម្រះ សម្រាប់ការជំទាស់របស់មេធាវីការពារក្តីទៅនឹងកំណត់ហេតុស្តាប់ចម្លើយ[16]

---

[12] ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារ E96/8/1 ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ដែលចាប់ពីពេលនេះតទៅហៅថា "ការជំទាស់ជាបឋមរបស់ នួន ជា" និងការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារE223/2/8 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ (ដែលចាប់ពីពេលនេះតទៅហៅថា "ការជំទាស់ជាចុងក្រោយរបស់ នួន ជា"។

[13] ការជំទាស់ជាចុងក្រោយរបស់ នួន ជា កថាខណ្ឌ ៦-១៥។ *សូមមើលផងដែរ* ការជំទាស់ជាបឋមរបស់ នួន ជា។

[14] ការជំទាស់ជាចុងក្រោយរបស់ នួន ជា កថាខណ្ឌ ៦-១៤។

[15] ឧបសម្ព័ន្ធបន្ថែមពាក់ព័ន្ធនឹងការជំទាស់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនានា ឯកសារE223/2/8/1 កថាខណ្ឌ ៥, ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (ដែលចាប់ពីពេលនេះតទៅហៅថា "ឧបសម្ព័ន្ធបន្ថែមរបស់ នួន ជា"។

[16] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារ E223) ឯកសារ E223/2 កថាខណ្ឌ ១៤ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (សម្រេចឱ្យមេធាវីការពារក្តីលើកការជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងកំណត់ហេតុស្តាប់ចម្លើយ រហូតដល់ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣)។

មេធាវីការពារក្តី នួន ជា បានធ្វើសេចក្តីសន្និដ្ឋានបន្ថែមស្តីពីកំណត់ហេតុស្តាប់ចម្លើយ[17] ដែលតាមរយៈសេចក្តីសន្និដ្ឋាននេះ មេធាវីការពារក្តីបានបន្ថែមការជំទាស់របស់ខ្លួនជាច្រើនទៅនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ដែលត្រូវបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី ដោយមេធាវីការពារក្តីបានបញ្ជាក់ថា “[ដោយសារ] ខ្វះខាតនូវធនធាន មេធាវីការពារក្តីមិនបានពិនិត្យមើលឡើងវិញចំពោះចម្លើយដែលបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណីកាលពីថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣” ប៉ុន្តែយ៉ាងណាក៏ដោយ បានទទូចថា “ការជំទាស់ [...] គឺអនុវត្តដូចគ្នាទៅនឹងចម្លើយទាំងនោះ”[18]។ មេធាវីការពារក្តី នួន ជា មិនបានលើកឡើងការជំទាស់ដាច់ដោយឡែក ទៅនឹងកំណត់ហេតុស្តាប់ចម្លើយណាមួយ ដែលបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

## III. ការពិភាក្សា

### *ក. ការជំទាស់របស់មេធាវីការពារក្តីទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំជំនួសឲ្យចម្លើយជាលាយលក្ខណ៍អក្សរ ត្រូវបានដាក់មិនទាន់ពេលវេលា និងខ្វះខាតនូវភាពជាក់លាក់*

11. នៅក្នុងការជំទាស់ចុងក្រោយទាំងមូលរបស់ នួន ជា ការយោងទៅលើដើមបណ្តឹងរដ្ឋប្បវេណី ឬកំណត់ហេតុស្តាប់ចម្លើយ ដែលដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យដាក់បញ្ចូលជាភ័ស្តុតាង ត្រូវបានលើកជាសំអាងចំនួនពីរដងនៅក្នុងកថាខណ្ឌដូចគ្នា និងការលើកឡើងទាំងពីរលើកគាំទ្រដល់ការអះអាងទូទៅរបស់មេធាវីការពារក្តីដែលថា “សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ ធ្វើហួសពីដែនកំណត់នៃភាពពាក់ព័ន្ធរបស់កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ដែលកំណត់ដោយអង្គជំនុំជម្រះ”[19] ឬស្ថិតនៅក្រៅវិសាលភាពសំណុំរឿង ០០២/០១។ នៅក្នុងសារណារបស់ខ្លួនដែលបញ្ចូលឧបសម្ព័ន្ធបន្ថែម ការដាក់សារណាមានភាពយឺតយ៉ាវចំនួន ៣ ថ្ងៃ *បន្ទាប់ពី*ការផុតកំណត់ការដាក់ឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង ដែលមេធាវីការពារក្តី នួន ជា ទទួលស្គាល់យ៉ាងច្បាស់ថាខ្លួនពិតជាមិនបានពិនិត្យមើលឡើងវិញចំពោះគំរូដែលជាតំណាង

---

[17] ឧបសម្ព័ន្ធបន្ថែមរបស់ នួន ជា។

[18] ការជំទាស់ជាចុងក្រោយរបស់ នួន ជា កថាខណ្ឌ ៤ (សំដៅទៅលើការជំទាស់ដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងសារណាកាលពីថ្ងៃទី ២៦ ខែ មេសា ដែលសំដៅស្ទើរតែទាំងស្រុងចំពោះព្រះរាជអាជ្ញា)។

[19] *ដូចខាងលើដែរ* កថាខណ្ឌ ២២។

ឲ្យកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[20]។ យ៉ាងណាក៏ដោយ មេធាវីការពារក្តី នួន ជា ទទួចថា ខ្លួនមិនគួរឲ្យទទួលខុសត្រូវចំពោះភាពខ្វះខាតនៃការពិនិត្យមើលត្រឹមត្រូវនោះទេ ប៉ុន្តែមេធាវីការពារក្តីបែរជាបញ្ជាក់ថា "ការខកខានក្នុងការបញ្ជាក់ច្បាស់លាស់អំពីការជំទាស់ មិនបានឆ្លុះបញ្ចាំងអំពីការសុខចិត្តព្រមទទួលយកនោះទេ"[21]។

12. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា "[ភាគី]ត្រូវបង្ហាញសេចក្តីជំទាស់ឲ្យបានច្បាស់លាស់ ហើយនៅពេលពុំមានការបញ្ជាក់ឲ្យបានច្បាស់លាស់គ្រប់គ្រាន់ មានតែការជំទាស់ដែលចោទប្រកាន់ថាឯកសារណាមួយខ្វះនូវភាពអាចជឿជាក់បាន ឬភាពជាប់ពាក់ព័ន្ធយ៉ាងច្បាស់ប៉ុណ្ណោះ ដែលនឹងត្រូវអង្គជំនុំជម្រះពិនិត្យពិចារណា"[22]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះបានសម្រេចថា ការជំទាស់ទៅលើភាពពាក់ព័ន្ធ ភាពអាចជឿទុកចិត្តបាន និងយថាភាពនៃឯកសារ "ចាំបាច់ត្រូវលើកឡើងនៅពេលដែលឯកសារមួយ ឬភ័ស្តុតាងផ្សេងទៀតកំពុងត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សំណើផ្សេងៗអំពីភាពអាចជឿជាក់បាននៃឯកសារ អង្គជំនុំជម្រះនឹងថ្លឹងថ្លែងសម្រេចចំពោះឯកសារនោះ"[23]។

13. មេធាវីការពារក្តី នួន ជា មិនបានបំពេញសូម្បីតែលក្ខខណ្ឌតម្រូវមូលដ្ឋានបំផុតដើម្បីលើកឡើងនូវការជំទាស់មានសុពលភាពទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ បន្ថែមពីលើនេះ ការជំទាស់យ៉ាងទូលំទូលាយបំផុតទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានដំបូងនៅក្នុង "ឧបសម្ព័ន្ធបន្ថែម" ដែលបានដាក់ដោយមេធាវីការពារក្តីក្រោយពេលផុតកំណត់នៃការដាក់ឯកសារ ហេតុដូច្នេះការជំទាស់នេះមិនបានដាក់ទាន់ពេលវេលាកំណត់នោះ

---

[20] *ដូចខាងលើដែរ* កថាខណ្ឌ ៤។

[21] *ដូចខាងលើដែរ* (*អក្សរផ្តេក* ត្រូវបានលុបចោល)។

[22] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារE185 កថាខណ្ឌ១៣ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ (ដែលចាប់ពីពេលនេះទៅហៅថា "សេចក្តីសម្រេចទាក់ទិននឹងក្របខណ្ឌឯកសារ"។

[23] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6 និង E158 ឯកសារE162 កថាខណ្ឌ២ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ដែលចាប់ពីពេលនេះទៅហៅថា "អនុស្សរណៈស្តីពីភាពអាចទទួលយកបាន"។

ទេ។ ផ្អែកលើមូលដ្ឋាននេះ ការជំទាស់ទាំងអស់របស់មេធាវីការពារក្តី នួន ជា ទៅលើគំរូដែលជាតំណាងឲ្យកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនត្រូវបានរៀបរាប់លំអិតនោះ ការជំទាស់ទាំងនោះត្រូវតែបដិសេធចោល។

14. ជាការច្បាស់ណាស់ថា ការជំទាស់ដែលមានសុពលភាព ត្រូវតែលើកឡើងពិតប្រាកដចំពោះភាគី ឬភ័ស្តុតាងរបស់ភាគីនោះ បើទោះជាការជំទាស់ទាំងនោះ មិនអាចរៀបរាប់លំអិតចំពោះឯកសារណាមួយក៏ដោយ។ នៅក្នុងទទ្បីករណ៍ជាច្រើន[24] មេធាវីការពារក្តីបានខកខានមិនបានបញ្ជាក់ថាការជំទាស់របស់ខ្លួន គឺសំដៅចំពោះកំណត់ហេតុស្តាប់ចម្លើយដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ អាស្រ័យហេតុនេះ ដើមបណ្តឹងរដ្ឋប្បវេណីផ្តោតការឆ្លើយតបរបស់ខ្លួនទៅលើការជំទាស់ទាំងឡាយណា ដែលមេធាវីការពារក្តីសំដៅចំពោះដើមបណ្តឹងរដ្ឋប្បវេណី ឬបញ្ជាក់ច្បាស់ទៅលើបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។

15. មេធាវីការពារក្តី ខៀវ សំផន ក៏បានខកខានមិនបានបញ្ជាក់ច្បាស់អំពីការជំទាស់របស់ខ្លួនទៅលើឯកសារចំនួន ៣៤ ដែលមាននៅក្នុងគំរូដែលជាតំណាងឲ្យកំណត់ហេតុរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហេតុដូច្នេះ ឯកសារទាំងនេះគួរតែត្រូវទទួលយកជាភ័ស្តុតាង[25]។

*ខ. ទទ្បីករណ៍ដែលមេធាវីការពារក្តីយកមកប្រើសាជាថ្មីចំពោះច្បាប់ដែលអនុវត្តទៅលើកំណត់ហេតុស្តាប់ចម្លើយ គឺមិនអាចទទួលយកបាននោះទេ*

16. ក្របខណ្ឌគតិយុត្តិសម្រាប់ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ដែលបានរៀបរាប់ដោយមេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន នៅក្នុងសេចក្តីជំទាស់របស់ពួកគាត់ មិនស្របទៅនឹងក្របខណ្ឌគតិយុត្តដែលមានចែងនៅក្នុងសេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយរបស់អង្គជំនុំជម្រះនោះទេ។ ទោះបីជាមានលក្ខណៈចងកាតព្វកិច្ចរបស់សេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយក៏ដោយ ក៏មេធាវីការពារក្តីបន្តទទូចថា ខ្លួនមិនត្រូវបានចងភ្ជាប់កាតព្វកិច្ច

---

[24] *សូមមើលឧទា.* ការជំទាស់ជាចុងក្រោយរបស់ នួន ជា កថាខណ្ឌ ២៤, ៣៥, ៤៣ (សំដៅការជំទាស់ទៅលើចរិតលក្ខណៈត្រួតគ្នានៃសក្ខីកម្ម ភ័ស្តុតាងនៃរចនាសម្ព័ន្ធរដ្ឋបាល ការបញ្ជា និងទំនាក់ទំនង និងទង្វើនិងការប្រព្រឹត្តរបស់ជនជាប់ចោទចំពោះព្រះរាជអាជ្ញា)។

[25] *សូមមើលដូចខាងលើ* ត្រង់កថាខណ្ឌ ៨។

ដោយវិធាន ឬសំអាងហេតុនោះទេ[26]។ ដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ថា ទឡ្ហីករណ៍របស់មេធាវីការពារក្ដី មានលក្ខណៈផ្សេងគ្នាដាច់ស្រឡះ ដែលវាដូចគ្នាទៅនឹងការបដិសេធចោលស្ទើរតែទាំងអស់នៃក្របខណ្ឌគតិយុត្តស្ដីពីកំណត់ហេតុស្ដាប់ចម្លើយ។

17. ដើមបណ្ដឹងរដ្ឋប្បវេណីគាំទ្រទាំងស្រុងចំពោះជំហររបស់សហព្រះរាជអាជ្ញាដែលថា "ការលើកឡើងរបស់មេធាវីការពារក្ដី គឺស្មើនឹងសំណើសុំឱ្យពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចទាក់ទិននឹងកំណត់ហេតុស្ដាប់ចម្លើយ" ហើយមេធាវីការពារក្ដីមិនបានបំពេញបុរេលក្ខខណ្ឌគតិយុត្តដែលចាំបាច់ ដើម្បីធ្វើសំណើបែបនោះ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ចូលដោយសំអាងលើទឡ្ហីករណ៍ជាច្រើនរបស់ព្រះរាជអាជ្ញា នៅក្នុងផ្នែកខាងក្រោយៗនៃការឆ្លើយតបនេះ។

***គ. ដើមបណ្ដឹងរដ្ឋប្បវេណីរម្លឹកអំពីការសម្រេចជាគន្លឹះរបស់អង្គជំនុំជម្រះសាលាដំបូង និងទឡ្ហីករណ៍ពីមុនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីភាពជាប់ពាក់ព័ន្ធ ភាពអាចជឿទុកចិត្តបាន (និងយថាភាព)នៃកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី***

18. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា "វិធាន៨៧(៣)នៃវិធានផ្ទៃក្នុង [...] តម្រូវឱ្យឯកសារដែលមានបំណងចង់ដាក់នៅអង្គជំនុំជម្រះ ត្រូវតែបំពេញបទដ្ឋាន *នៃសេចក្ដីបញ្ជាក់ដំបូង* នៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពនៃឯកសារនោះផង"[27] និង "ឧទាហរណ៍ ប្រសិនបើឯកសារមួយមិនបានបង្ហាញថា ក្លែងក្លាយ ឬជាឯកសារមិនតំណាងឱ្យឯកសារដើមក្ដី ឯកសារនេះនឹងត្រូវចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ [...] សំណើផ្សេងៗអំពីភាពអាចជឿជាក់បាននៃឯកសារ អង្គជំនុំជម្រះនឹងថ្លឹងថ្លែងសម្រេចចំពោះឯកសារនោះ"[28]។

---

[26] *សូមមើលខទា.* សេចក្ដីសន្និដ្ឋានរបស់ ខៀវ សំផន អនុលោមតាមវិធាន៩២ កថាខណ្ឌ៣៥ (រៀបរាប់អំពីការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូងចំពោះ "ធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មអន្តរជាតិ" ថាជាធាតុផ្សំស្របច្បាប់ដើម្បីវាយតម្លៃភាពពាក់ព័ន្ធ ភាពអាចជឿទុកចិត្ត និងយថាភាពនៃកំណត់ហេតុស្ដាប់ចម្លើយ ថាជា "កំហុសអង្គច្បាប់") និងការជំទាស់ជាចុងក្រោយរបស់ នួន ជា កថាខណ្ឌ ៦-១៣។

[27] ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៨៥-៨៨ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* សេចក្ដីសម្រេចទាក់ទិននឹងឯកសារក្របខណ្ឌ កថាខណ្ឌ២០។ និង អនុស្សរណៈស្ដីពីភាពអាចទទួលយកបាន កថាខណ្ឌ២។

[28] ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៨៥-៨៨ (ភាសាអង់គ្លេស)។

19. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចម្តងហើយម្តងទៀតថា "សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃឯកសារទាំងអស់ដែលបានដាក់នៅក្នុងសំណុំរឿង ដើម្បីកំណត់នូវភាពពាក់ព័ន្ធ" ហើយ "អង្គជំនុំជម្រះសាលាដំបូងធ្វើការសន្មតទៅលើឯកសារនានាក្នុងដំណាក់កាលដំណោះស្រាយថា មានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន រួមទាំងយថាភាពរបស់វាផង"[29]។ បន្ថែមពីលើនេះ "នៅពេលដែលមានការចោទប្រកាន់អំពីភាពខ្វះចន្លោះនៅក្នុងកំណត់ហេតុទាំងនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា ប្រការនេះនឹងត្រូវបានពិចារណា នៅពេលដែលមានការចង្អុលបង្ហាញច្បាស់លាស់គ្រប់គ្រាន់អំពីចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់ និងមានភាពពាក់ព័ន្ធច្បាស់លាស់ទៅនឹងសវនាការតែប៉ុណ្ណោះ"[30]។

20. ទោះបីជាមេធាវីការពារក្តី មិនបានជំទាស់ឲ្យជាក់លាក់ទៅនឹងភាពជឿជាក់នៃកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ច.ស ដែលមាននៅក្នុងគំរូដែលជាតំណាងឲ្យកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា មានឯកសារប្រភេទនេះចំនួន៥៤ នៅក្នុងតារាងថ្ងៃទី ០៤ ខែ មីនា របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារចំនួនបីនៃឯកសារទាំងនេះ ត្រូវបានអង្គជំនុំជម្រះកំណត់ជាប្រភេទឯកសារលេខE3 រួចរាល់ហើយ អាស្រ័យហេតុនេះឯកសារទាំងនេះ ត្រូវបានទទួលយកជាភស្តុតាង។

21. ពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយដែលមិនត្រូវបានធ្វើឡើងដោយ ក.ស.ច.ស មេធាវីការពារក្តីអះអាងថា "កំណត់ហេតុណាមួយដែលមិនត្រូវបានធ្វើឡើងដោយតំណាងរបស់ ក.ស.ច.ស តំណាងសហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលយកបានទេ ពីព្រោះតែកំណត់ហេតុទាំងនោះ មិនបានឃើញដោយមន្ត្រីតុលាការ ដូចដែលបានតម្រូវដោយវិធាន ៩២ ស្ទួន (ខ) របស់តុលាការ ICTY/R ឡើយ"[31]។ ស្រដៀងគ្នានេះដែរ មេធាវីការពារក្តី ខៀវ សំផន លើកទទ្បីករណ៍ថា ឯកសារជាច្រើនរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលយកបានទេ ដោយផ្អែកលើមូលដ្ឋានថា អង្គភាពដែលធ្វើកំណត់ហេតុនេះមានផលប្រយោជន៍ចំពោះការផ្តន្ទាទោសជនជាប់

[29] *ដូចខាងលើដែរ*។

[30] សេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ២៦។

[31] ការជំទាស់ជាចុងក្រោយរបស់ នួន ជា កថាខណ្ឌ៤២។

ចោទចំពោះឧក្រិដ្ឋកម្មទាំងនោះ[32]។ ទាំងក្រុមមេធាវីការពារក្ដី ខៀវ សំផន និងក្រុមមេធាវីការពារក្ដី នួន ជា មិនបានបង្ហាញច្បាស់អំពីមូលហេតុជាក់លាក់ណាមួយ ដើម្បីគាំទ្រចំពោះការអះអាងរបស់ខ្លួនដែលថា កំណត់ហេតុទាំងនោះមិនអាចជឿជាក់បាននោះ។

22. អង្គជំនុំជម្រះសាលាដំបូងមានចេតនាលុបចោលលក្ខខណ្ឌ ដែលតម្រូវឱ្យបញ្ជាក់តាមវិធាន ៩២ ចេញពីក្របខណ្ឌគតិយុត្ត ដែលខ្លួនបានបង្កើតនៅក្នុងសេចក្ដីសម្រេចទាក់ទិននឹងកំណត់ហេតុស្ដាប់ចម្លើយ ប៉ុន្តែអង្គជំនុំជម្រះបែរជាបង្កើតប្រព័ន្ធមួយដែលអនុញ្ញាតឱ្យភ័ស្តុតាងបែបនោះ អាចស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន៨៧(១) នៃវិធានផ្ទៃក្នុង[33]។ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ អង្គជំនុំជម្រះបានលើកឡើងថា សូចនាករនៃភាពជឿទុកចិត្តអាចជួយដល់អង្គជំនុំជម្រះនៅក្នុងការកំណត់អំពីភាពអាចទទួលយកបាន និងតម្លៃជាភ័ស្តុតាងនៃភ័ស្តុតាងបែបនោះ[34]។

23. ទោះបីជាកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចត្រូវបានសន្មតអំពីភាពអាចជឿជាក់ក៏ដោយ[35] ក៏ក្របខណ្ឌគតិយុត្តិដែលបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនទាក់ទិននឹងកំណត់ហេតុស្ដាប់ចម្លើយ បានលំអិតអំពីឆន្ទានុសិទ្ធិទូលំទូលាយរបស់អង្គជំនុំជម្រះក្នុងការទទួលយកឯកសារនានាជាភ័ស្តុតាង និងការផ្ដល់នូវតម្លៃជាភ័ស្តុតាង[36]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្អែកលើគោលការណ៍ទាំងនេះដើម្បីបង្ហាញភ័ស្តុតាងអំពី

---

[32] *សូមមើលជាទូទៅ* សេចក្ដីជំទាស់របស់លោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី សុំដាក់ឱ្យពិភាក្សាដេញដោលនូវកំណត់ហេតុស្ដាប់ចម្លើយមួយចំនួន ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារលេខ E208/5.7 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("ការជំទាស់ដាច់ដោយឡែករបស់ ខៀវ សំផន"។

[33] សេចក្ដីសម្រេចទាក់ទិននឹងកំណត់ហេតុស្ដាប់ចម្លើយ កថាខណ្ឌ២៩។

[34] *ដូចខាងលើដែរ។*

[35] *ដូចខាងលើដែរ។*

[36] *ដូចខាងលើដែរ* កថាខណ្ឌ២៤ (កត្តាដែលគាំទ្រដល់ការទទួលយកភ័ស្តុតាង រួមមានថាតើភ័ស្តុតាងនេះ៖ ១)មានចរិតលក្ខណៈត្រួតគ្នា ដែលនៅក្នុងនោះសាក្សី(និងដើមបណ្ដឹងរដ្ឋប្បវេណី)នឹងផ្ដល់ ឬបានផ្ដល់រួចហើយនូវសក្ខីកម្មផ្ទាល់មាត់លើអង្គហេតុស្រដៀងគ្នា។ ២) មានការទាក់ទងនឹងសាវតារជាប្រវត្តិសាស្ត្រ ជានយោបាយ ឬជាយោធា ដែលពាក់ព័ន្ធទៅនឹងភ័ស្តុតាងនៃកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ឬផ្ដល់សក្ខីកម្មអំពីកម្រិតធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ។ ៣)មានការវិភាគមួយជាទូទៅ ឬជាស្ថិតិស្ដីពីសមាសភាគជាតិពន្ធុនៃប្រជាជននៅតាមទីកន្លែងនានា ដែលមានការទាក់ទងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ៤) ពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ។ ឬ ៥) មិនអាចដាក់ឱ្យស្ថិតនៅក្រោមការតទល់គ្នា ពីព្រោះក្រោយមក

ភាពពាក់ព័ន្ធនៃកំណត់ហេតុនានាដែលមាននៅក្នុងគំរូដែលជាតំណាង ដោយរួមបញ្ចូលទាំងការលំអិតកត្តាទាំងនេះនៅក្នុងតារាងដែលមានចំណងជើង “គោលបំណងនៃភ័ស្តុតាង” នៅក្នុងតារាងថ្ងៃទី ០៤ ខែ មីនា របស់ដើមបណ្តឹងរដ្ឋប្បវេណី។

24. ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការលើកឡើងមួយចំនួនដែលលំអិតលើទឡ្ហីករណ៍បន្ថែម ដើម្បីគាំទ្រភាពពាក់ព័ន្ធ និងភាពជាក់ជឿជាក់នៃកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី[37]។ ចំពោះភាពជឿជាក់នៃកំណត់ហេតុស្តាប់ចម្លើយដែលមិនបានធ្វើឡើងដោយ ក.ស.ច.ស ដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូល ដោយសំអាងលើសារណាពីមុនរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើចំណុចនេះ[38]។ នៅក្នុងចម្លើយតបនោះ ដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់ស្ថានភាពដែលផ្នែកនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានប្រមូល និងដំណើរការ និងសូចនាករនៃភាពជឿទុកចិត្ត ដែលគាំទ្រដល់ការទទួលយក និងផ្តល់តម្លៃជាភ័ស្តុតាងចំពោះឯកសារទាំងនេះ៖ “សូចនាករនៃភាពជឿទុកចិត្តបន្ថែមនៅក្នុងដំណើរការនេះ រួមមានអង្គហេតុដែលថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងសាក្សី។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលការស្បថ និងការអះអាងថា ព័ត៌មានទាំងអស់ដែលបានផ្តល់ក្នុងបែបបទនេះ ពិតជាត្រឹមត្រូវពិតប្រាកដមែន ហើយប្រសិនបើមានចំណុចណាមិនពិត នឹងសូមទទួលទោសតាមច្បាប់ជាធរមាន”[39]។

25. ដោយសារតែពុំមានទឡ្ហីករណ៍ច្បាស់លាស់ណាមួយរបស់មេធាវីការពារក្តី ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា កំណត់ហេតុស្តាប់ចម្លើយមិនអាចជឿទុកចិត្ត និងដោយពិចារណាទៅលើ

---

សាក្សីផ្តល់ចម្លើយនោះបានស្លាប់ ឬមិនអាចតាមរកឃើញ ឬមានបញ្ហាសុខភាពដែលមិនអាចមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់បាន។ (បានសង្ខេបដោយខ្លី)។

[37] *សូមមើល* ចម្លើយតបទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/5 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (ដែលចាប់ពីពេលនេះតទៅហៅថា “ចម្លើយតបទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយលើកទីមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី”)។

[38] ចម្លើយតបទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយលើកទីពីររបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៤-២៥។

[39] *ដូចខាងលើដែរ* កថាខណ្ឌ២។

សូចនាករនៃភាពជឿទុកចិត្តជាច្រើនដែលពាក់ព័ន្ធនឹងឯកសារទាំងនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបំពេញបទដ្ឋាន *សេចក្តីបញ្ជាក់ដំបូង*របស់អង្គជំនុំជម្រះ សម្រាប់បង្កើតបានជាភាពជឿជាក់នៃឯកសារទាំងនេះ។ ទឡ្ហីករណ៍បន្ថែម ដែលទាក់ទិននឹងភាពពាក់ព័ន្ធកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងលើកឡើងបន្តបន្ទាប់ទៀត។

## *ឃ. ភ័ស្តុតាងដែលមាននៅក្នុងគំរូនៃកំណត់ហេតុស្តាប់ចម្លើយដែលជាតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី គឺស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១*

26. ដោយយោងទៅលើគោលបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការស្នើសុំឱ្យទទួលយកភ័ស្តុតាង "ក្នុងចំណោមគោលនយោបាយទាំងប្រាំរបស់កម្ពុជាប្រជាធិបតេយ្យ និងភ័ស្តុតាងអំពីទីតាំងឧក្រិដ្ឋកម្មទាំងអស់នៅក្នុងដីកាដំណោះស្រាយ" មេធាវីការពារក្តី នួន ជា អះអាងថា "សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់កំណត់ហេតុស្តាប់ចម្លើយ ធ្វើហួសពីដែនកំណត់នៃភាពពាក់ព័ន្ធរបស់កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ដែលកំណត់ដោយអង្គជំនុំជម្រះ"[40]។ ស្រដៀងគ្នានេះដែរ មេធាវីការពារក្តី ខៀវ សំផន លើកទឡ្ហីករណ៍ថា ភ័ស្តុតាងតែមួយគត់ដែលអាចទទួលយកបានអំពីគោលនយោបាយទាំងនោះគឺពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ និងទួលពោធិ៍ជ្រៃ[41]។

27. ត្រង់ចំណុចនេះ ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រ និងដាក់បញ្ចូលចំណុចនេះ ដោយយោងទៅលើទឡ្ហីករណ៍របស់ព្រះរាជអាជ្ញា[42]។ ដូចដែលបានរៀបរាប់ដោយព្រះរាជអាជ្ញា ភ័ស្តុតាងដែលប្រើប្រាស់សម្រាប់អត្ថិភាពនៃគោលនយោបាយទាំងប្រាំ ដែលបង្កើតសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែមិនមែនការអនុវត្តគោលនយោបាយទាំងនោះឡើយ ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដូចដែលបានចង្អុលបង្ហាញតាមរយៈការទទួលយកភ័ស្តុតាងបែបនេះរបស់អង្គជំនុំជម្រះសាលាដំបូង តាមរយៈការធ្វើសក្ខីកម្មដោយផ្ទាល់មាត់[43]។ ចំណុចនេះត្រូវបានផ្តល់ភ័ស្តុតាងបញ្ជាក់បន្ថែមទៀត ដោយអង្គហេតុដែលថា បញ្ជីកថាខណ្ឌនានា

---

[40] ការជំទាស់ជាចុងក្រោយរបស់ នួន ជា កថាខណ្ឌ ២២។

[41] ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២៨-២៩។

[42] ដូចយោងខាងលើ កថាខណ្ឌ ៣១-៣៦។

[43] ដូចយោងខាងលើ កថាខណ្ឌ ៣។

នៃដីកាដំណោះស្រាយនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះផ្ទាល់ ដាក់បញ្ចូលគោលនយោបាយទាំងឡាយណាដែលបង្កើតឲ្យមានសហឧក្រិដ្ឋកម្មរួម[44]។

28. ភស្តុតាងដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលពាក់ព័ន្ធ ដែលបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី សំដៅបញ្ជាក់អំពីអត្ថិភាពនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ មិនមែនការអនុវត្តគោលនយោបាយទាំងនោះទេ ដូចដែលបានកត់សម្គាល់នៅក្នុងផ្នែកនៃតារាងថ្ងៃទី ៤ ខែ មីនា ត្រង់ចំណុចគោលបំណងនៃភស្តុតាង។

29. ភស្តុតាងដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់ជូននោះគឺជាប្រភពដ៏សំខាន់នៃភស្តុតាងបញ្ជាក់អំពីអត្ថិភាពនៃគោលនយោបាយ ដែលត្រូវបានចោទប្រកាន់ពីព្រោះវាបានមកពីជនរងគ្រោះនៃរបបនេះ ដែលពួកគាត់ត្រូវបានគេបំពាក់បំប៉នស្មារតី ហើយជីវិតរបស់ពួកគាត់ត្រូវបានដឹកនាំដោយគោលនយោបាយទាំងនោះជាប្រចាំរាល់ថ្ងៃ នៅទូទាំងប្រទេស។ លើសពីនេះទៀត នៅក្នុងកាលៈទេសៈដែលជនជាប់ចោទបដិសេធអត្ថិភាពនៃគោលនយោបាយទាំងនេះ និងឯកសារជាលាយលក្ខណ៍អក្សរដែលកំណត់នូវវិសាលភាព ហើយការពិពណ៌នាអំពីរូបភាពនៃគោលនយោបាយទាំងនេះមានកំណត់នោះ ការពិពណ៌នារបស់បុគ្គលទាំងឡាយដែលបានរស់នៅក្រោមគោលនយោបាយទាំងនេះ គឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការបញ្ជាក់អំពីអត្ថិភាពនៃគោលនយោបាយទាំងនេះ។ ដូច្នេះ កំណត់ហេតុស្តាប់ចម្លើយដែលបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសហឧក្រិដ្ឋកម្មរួម និងគោលនយោបាយ គឺជាប់ពាក់ព័ន្ធ *បឋម*។

## *ង. កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវគ្នាទៅនឹងសក្ខីកម្មដោយផ្ទាល់មាត់ដែលបានផ្តល់ជូនក្នុងសំណុំរឿង ០០២/០១*

[44] បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងសំណុំរឿង ០០២/០១ ដែលធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163) ឯកសារ **E124/7.3** ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ (រួមទាំង ជាពិសេសកថាខណ្ឌ ១៥៦-១៥៩ ស្តីពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម)។

30. កំណត់ហេតុស្តាប់ចម្លើយដែលមាននៅក្នុងគំរូដែលជាតំណាងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវភ័ស្តុតាងដ៏សំខាន់យ៉ាងពិសេស និងអាចទទួលយកបានទាំងស្រុង ដែលមានលក្ខណៈត្រួតគ្នាទៅនឹងភ័ស្តុតាងដែលបានផ្តល់ជូនអំពីអង្គហេតុស្រដៀងគ្នា តាមរយៈសក្ខីកម្មដោយផ្ទាល់មាត់របស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០១។ ការចង្អុលបង្ហាញអំពីព័ត៌មាននេះត្រូវបានផ្តល់ជូន នៅក្នុងចំណុចគោលបំណងនៃភ័ស្តុតាង ដែលបញ្ជាក់នៅក្នុងតារាងថ្ងៃទី ៤ ខែ មីនា របស់ដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ឯកសារនីមួយៗ។ ទាក់ទិននឹងលក្ខខណ្ឌដែលថាភ័ស្តុតាងនេះត្រួតលើគ្នាទៅនឹងភ័ស្តុតាង (ឬអង្គហេតុស្រដៀងគ្នាទៅនឹងភ័ស្តុតាង) ដែលបានផ្តល់ជូនតាមរយៈសក្ខីកម្មដោយផ្ទាល់មាត់នោះ យើងសូមយោងទៅលើឧទាហរណ៍នៃសក្ខីកម្មដោយផ្ទាល់មាត់ ដែលបានផ្តល់ជូននៅក្នុងចម្លើយតបរបស់ព្រះរាជអាជ្ញា[45]។

### *ច. លក្ខណៈវិនិច្ឆ័យរបស់មេធាវីការពារក្តីសម្រាប់ដកចេញនូវភ័ស្តុតាង ដោយផ្អែកទៅលើមូលដ្ឋាននៃ "ទង្វើ និងការប្រព្រឹត្ត" គឺមានលក្ខណៈទូលំទូលាយណាស់ ហើយការជំទាស់របស់ខ្លួន ដោយផ្អែកលើមូលដ្ឋាននៃការកោសលុបឯកសារ គឺមិនត្រឹមត្រូវឡើយ*

31. នៅក្នុងសារណារបស់ខ្លួន មេធាវីការពារក្តី នួន ជា បកស្រាយឃ្លា "ទង្វើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[46] ដើម្បីដាក់បញ្ចូលមិនត្រឹមតែទង្វើរបស់ នួន ជា ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទង្វើរបស់ "ក្រុមមួយដែលរូបគាត់ត្រូវបានលើកឡើងថាជាសមាជិករបស់ក្រុមនោះ" ទៀតផង[47]។ ផ្ទុយទៅនឹងសារណាពីមុនរបស់ខ្លួន[48] មេធាវីការពារក្តីក៏អះអាងផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីទទួលបន្ទុកកោសលុបចម្លើយទាំងអស់ដែលត្រូវបានបដិសេធ ស្តីអំពីទង្វើ និងការប្រព្រឹត្ត ពីកំណត់ហេតុស្តាប់ចម្លើយ[49]។

---

[45] ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ៣៧-៤៤។

[46] វិធាន៩២ស្ទួន(ក) នៃតុលាការ ICTY/ICTR ។

[47] ឧបសម្ព័ន្ធបន្ថែមរបស់ នួន ជា កថាខណ្ឌ ៥(ខ)។

[48] ការជំទាស់ជាបឋមរបស់ នួន ជា កថាខណ្ឌ ១៥ (ដែលកត់សម្គាល់ថា "អង្គជំនុំជម្រះជាទម្លាប់កោសលុបផ្នែកកំណត់ហេតុដែលមិនអាចទទួលយកជាភ័ស្តុតាងនៅមុនពេលដែលកំណត់ហេតុនេះអាចទទួលយកជាភ័ស្តុតាង")។

[49] ឧបសម្ព័ន្ធបន្ថែមរបស់ នួន ជា កថាខណ្ឌ ៤៤-៤៥។

32. មេធាវីការពារក្តី ខៀវ សំផន លើកឡើងនូវទស្សនៈកាន់តែទូលំទូលាយថែមទៀតអំពីទង្វើ និងការប្រព្រឹត្ត រួមទាំងភ័ស្តុតាងដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវ តាមឋានុក្រមរបស់ជនជាប់ចោទ វចនាសម្ព័ន្ធ ក្នុងការធ្វើសេចក្តីសម្រេចរបស់កម្ពុជាប្រជាធិបតេយ្យ និងវចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន[50] និងអះអាងថា ភាពខុសគ្នាណាមួយរវាងភ័ស្តុតាងដែលសំដៅទៅលើអត្ថិភាពនៃគោលនយោបាយ និងទង្វើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ គឺ "ក្លែងក្លាយទាំងស្រុង"[51]។ ខៀវ សំផន ក៏បានអះអាងផងដែរថា ផ្នែកណាដែលមិនត្រូវបានទទួលយកនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានស្នើឡើង ដែលភាគីមានបំណងយកមកធ្វើជាមូលដ្ឋាននោះ ត្រូវតែកំណត់ដោយភាគីដាក់ឯកសារ បើពុំដូច្នោះទេ កំណត់ហេតុស្តាប់ចម្លើយទាំងមូល "ត្រូវតែបដិសេធចោលទាំងស្រុង"[52]។ វិធីសាស្ត្រនេះជាមូលដ្ឋាននៃទឡ្ហីករណ៍របស់មេធាវីការពារក្តី ទៅលើការជំទាស់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះ មេធាវីការពារក្តីស្នើសុំឲ្យមានការដកចេញនូវកំណត់ហេតុទាំងនោះ ដោយផ្អែកលើមូលដ្ឋានថា មានតែផ្នែកមួយប៉ុណ្ណោះនៃខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយ មិនត្រូវបានអនុញ្ញាត[53]។

33. ទាក់ទិននឹងវិសាលភាពសមស្របនៃទង្វើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រ និងដាក់បញ្ចូលចំណុចនេះដោយយោងទៅលើទឡ្ហីករណ៍[54]។ លើសពីនេះទៀត ពួកគាត់សង្កត់ធ្ងន់ថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលយកទស្សនៈទូលំទូលាយហួសហេតុរបស់មេធាវីការពារក្តីអំពីអំពើ និងការប្រព្រឹត្ត នឹងនាំឲ្យទស្សនៈនេះឥតប្រយោជន៍។

34. ទាក់ទិននឹងកាតព្វកិច្ចរបស់ភាគីក្នុងការកោសលុបភ័ស្តុតាងដែលមិនអាចទទួលយកនៃទង្វើ និងការប្រព្រឹត្ត ពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនោះ ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រការ

---

[50] សូមមើលការជំទាស់ដាច់ដោយឡែករបស់ ខៀវ សំផន (ឧទាហរណ៍ ឯកសារលេខ D22/3850, d230/2/10 និង E9/32.2.28 ស្តីពីការទទួលខុសត្រូវតាមឋានានុក្រម។ ឯកសារលេខ d151/1, D2-1 និង D22/140 ស្តីពីវចនាសម្ព័ន្ធក្នុងការធ្វើសេចក្តីសម្រេច។ និងឯកសារលេខ d230/2/10 ស្តីពីវចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន)។

[51] សូមមើល ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២១។

[52] ដូចយោងខាងលើ កថាខណ្ឌ ៤៤-៥។

[53] សូមមើល ការជំទាស់ដាច់ដោយឡែករបស់ ខៀវ សំផន (ឧទាហរណ៍ ឯកសារលេខ D129/1, D145/2, D169/3, D217/3, D22/1140) ។

[54] ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ១៤-២៦។

អះអាងពីមុនរបស់ នួន ជា ដែលថា អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* ការកោសលុបបែបនេះត្រូវបានធ្វើឡើងដោយសមស្របដោយអង្គជំនុំជម្រះ នៅពេលទទួលយកឯកសារនោះជាភ័ស្តុតាង[55]។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអង្គជំនុំជម្រះសន្និដ្ឋានថា ឯកសារដែលបានផ្តល់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណី មានឯកសារដែលមិនអាចទទួលយកបានស្តីអំពីទង្វើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ហើយ បង្គាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីកោសលុបភ័ស្តុតាងនេះដោយខ្លួនឯង ពួកគាត់នឹងធ្វើការកោសលុប[56]។ នៅក្នុងផលប្រយោជន៍នៃភាពច្បាស់លាស់ ពួកគាត់នឹងពេញចិត្តនឹងធ្វើការកោសលុប នៅពេលដែលអង្គជំនុំជម្រះបានសម្រេចលើការជំទាស់របស់មេធាវីការពារក្តី។

35. ទាក់ទិននឹងការអះអាងរបស់ ខៀវ សំផន ដែលថា កំណត់ហេតុស្តាប់ចម្លើយទាំងស្រុងអាចត្រូវបានដកចេញពីភ័ស្តុតាង ដោយសារតែកំណត់ហេតុនេះមានខ្លឹមសារដែលមិនអាចទទួលយកបានដែល "ពុំមានការចង្អុលបង្ហាញ" ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា នេះគឺជាគោលជំហរដែលគ្មានអ្វីជាសំអាង មិនអាចអនុវត្តបាន និងមិនចាំបាច់ឡើយ។ ដោយពិចារណាលើទស្សនៈតិចតួចបំផុតដែលមេធាវីការពារក្តី ខៀវ សំផន មានទៅលើភ័ស្តុតាងដែលអាចទទួលយកបាននៅក្នុងសំណុំរឿង ០០២ និងអង្គហេតុដែលថា អង្គជំនុំជម្រះពុំទាន់បានសម្រេចលើការជំទាស់របស់ខ្លួននោះដើមបណ្តឹងរដ្ឋប្បវេណីមិនអាចចង្អុលបង្ហាញ ខ្លឹមសារដែលមិនអាចទទួលយកបាន*ជាអាទិកាល* *(a priori)* ឡើយ។ លើសពីនេះទៀត នៅក្នុងតុលាការ ដែលអនុវត្តគោលការណ៍ច្បាប់ស៊ីវិលឡ (civil law) នៃការទទួលយកភ័ស្តុតាងដោយសេរី[57] ការជំនុំជម្រះដែលត្រូតពិនិត្យដោយចៅក្រមដែលមានវិជ្ជាជីវៈ[58] និងក្របខណ្ឌច្បាប់ដែលអនុញ្ញាតឲ្យចៅក្រមទាំងនេះ មានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការទទួលយកភ័ស្តុតាង វាជាការយល់ខុសក្នុងការអះអាងថា លក្ខណៈខាងក្រៅតែមួយគត់

---

[55] ការជំទាស់ជាបឋមរបស់ នួន ជា កថាខណ្ឌ ១៥។

[56] មេធាវីការពារក្តី ខៀវ សំផន បានចង្អុលបង្ហាញឯកសារតិចជាង ១០ឯកសារពីក្នុងចំណោមគំរូដែលជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលមេធាវីការពារក្តីស្នើសុំឲ្យដកចេញ ដោយផ្អែកលើមូលដ្ឋាននេះ។

[57] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[58] សូមមើល សេចក្តីសម្រេចទាក់ទិននឹងក្របខណ្ឌឯកសារ កថាខណ្ឌ ២១(៦) (ដែលដកស្រង់ថា "វាមិនចាំបាច់នោះទេពីព្រោះថា ចៅក្រមវិជ្ជាជីវៈមានសមត្ថភាពក្នុងការដកចេញនូវភ័ស្តុតាងទាំងឡាយណាដែលមានលក្ខណៈបុរេវិនិច្ឆ័យមិនត្រឹមត្រូវ" ទឡ្ហីករណ៍របស់មេធាវីការពារក្តីគឺថា ភ័ស្តុតាងគួរត្រូវដកចេញ ប្រសិនបើតម្លៃនៃភ័ស្តុតាងនោះមានលក្ខណៈលម្អៀងជាខ្លាំងតាមតម្រូវការនៃការធានាឲ្យមានការជម្រះក្តីប្រកបដោយយុត្តិធម៌)។

ប៉ុណ្ណោះនៃភស្តុតាងដែលអាចមិនពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន អាចនាំឱ្យមានការដកចេញនូវភស្តុតាងដែលពាក់ព័ន្ធដទៃទៀតនៅក្នុងឯកសារតែមួយនេះ ជាពិសេសនៅពេលដែលភស្តុតាងដែលពាក់ព័ន្ធ គឺជាភស្តុតាងអំពីទីកន្លែងឧក្រិដ្ឋកម្ម ឬម៉្យាងវិញទៀតមិនត្រូវបានហាមឃាត់ ដោយផ្អែកលើ "ទង្វើ និងការប្រព្រឹត្ត"។

## ឆ. *ការអះអាងរបស់មេធាវីការពារក្តីដែលថា បញ្ហាអំពី "ភាពនៅជិតបំផុត" "បញ្ហាសំខាន់" និង "បញ្ហាចោទ" តម្រូវឱ្យមានការស្តាប់ចម្លើយរបស់ម្ចាស់ចម្លើយនៅកំណត់ហេតុស្តាប់ចម្លើយ បើពុំដូច្នេះទេ ភស្តុតាងជាលាយលក្ខណ៍អក្សររបស់ពួកគេត្រូវបដិសេធចោលនោះ គឺមិនមានហេតុផលត្រឹមត្រូវឡើយ*

36. មេធាវីការពារក្តីអះអាងថា សិទ្ធិពេញលេញក្នុងការសួរដេញដោលម្ចាស់ចម្លើយមានអត្ថិភាព នៅក្នុងកាលៈទេសៈជាច្រើនយ៉ាងទូលំទូលាយ រួមទាំងកាលៈទេសៈដែលអំពើល្មើសនៅជិតបំផុតនឹងជនជាប់ចោទ ឬពាក់ព័ន្ធនឹង "បញ្ហាសំខាន់" នៃ "សារៈសំខាន់គ្រប់គ្រាន់"[59]។ មេធាវីការពារក្តីកំណត់បញ្ហាទាំងនេះថាជា "បញ្ហាសំខាន់" ឬ "បញ្ហាចោទ" ដែលមានច្រើនប្រភេទដូចការអះអាងអំពីភាពមិនច្បាស់លាស់នៅក្នុងធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមូលដ្ឋានអង្គហេតុចំពោះការផ្លាស់ទីលំនៅដោយបង្ខំ[60]។

37. ដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របយ៉ាងពេញលេញ ជាមួយនឹងការវិភាគរបស់ព្រះរាជអាជ្ញាអំពីទទ្បីករណ៍ទាំងនេះថាមានលក្ខណៈទូលំទូលាយហួសហេតុ ហើយការយកទទ្បីករណ៍ទាំងនេះមកអនុវត្តគឺមិនចាំបាច់ឡើយ នៅក្នុងក្របខណ្ឌគតិយុត្តរបស់តុលាការនេះស្តីពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយ។ ជាពិសេស ពួកគាត់សង្កត់ធ្ងន់ថា ទទ្បីករណ៍របស់មេធាវីការពារក្តីមានលក្ខណៈទូលំទូលាយហួសហេតុ ដែលធ្វើឱ្យការកំណត់ពីភាពខុសគ្នារវាងភស្តុតាងដែលអាចទទួលយកបាន និងភស្តុតាងដែលមិនអាចទទួលយកបាននោះ មិនអាចធ្វើទៅបាន។ ចុងក្រោយ ពួកគាត់ផ្តោតទៅលើអង្គហេតុដែលថា ទទ្បីករណ៍របស់មេធាវីការពារក្តី ជាពិសេសទទ្បីករណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងការមិនទទួលយកភស្តុតាង ដែលមានគោលបំណងបញ្ជាក់អំពីធាតុផ្សំទូទៅនៃ

[59] ការជំទាស់ជាបឋមរបស់ នួន ជា កថាខណ្ឌ ១២។ សូមមើល ផងដែរ ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២៥។
[60] ដូចយោងខាងលើ កថាខណ្ឌ ៣៧។ និងសេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន អនុលោមតាមវិធាន ៩២ កថាខណ្ឌ ៣៥។

ឧក្រិដ្ឋកម្មអន្តរជាតិ[61] មានភាពផ្ទុយគ្នាដោយផ្ទាល់ទៅនឹងក្របខណ្ឌគតិយុត្តិ ដែលកំណត់នៅក្នុង សេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយ[62]។

***ជ. ចំនួនសម្ភារដែលមាននៅក្នុងគំរូដែលជាតំណាងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី គឺសមហេតុផលនៅក្នុងបរិបទនៃការជំនុំជម្រះអំពីបរិបទ និងភាពស្មុគស្មាញនៃសំណុំរឿង ០០២/០១។***

38. មេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីកម្រិតចំនួននៃកំណត់ហេតុស្តាប់ចម្លើយ ដែលអង្គជំនុំជម្រះទទួលយកក្នុង "ទំហំសមស្រប"[63] ដោយមិនបានផ្តល់នូវការបញ្ជាក់បន្ថែមឲ្យបានច្បាស់ឡើយថា ទំហំប៉ុណ្ណាដែលជាទំហំសមស្របសម្រាប់ការជំនុំជម្រះអំពីវិសាលភាព និងភាពស្មុគស្មាញនៃសំណុំរឿង ០០២/០១។ មេធាវីការពារក្តី នួន ជា អះអាងថា "កំណត់ហេតុស្តាប់ចម្លើយដែលត្រួតគ្នាមិនចាំបាច់ មិនអាចទទួលយកបានឡើយ ដោយផ្អែកលើហេតុផលថា កំណត់ហេតុទាំងនេះកម្រិតនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[64] ហើយថា "កង្វះនូវធនធាន" ធ្វើឲ្យមេធាវីការពារក្តីមិនមានលទ្ធភាពអាចពិនិត្យឡើងវិញឲ្យបានត្រឹមត្រូវលើកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី[65]។

39. ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីនៅតែប្រកាន់ខ្ជាប់នូវជំនឿដ៏មុតមាំថា កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង គួរតែអង្គជំនុំជម្រះសាលាដំបូងយកមកពិចារណាដើម្បីឈានទៅដល់ការចេញសាលក្រមនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ដោយសារតែកំណត់ហេតុទាំងនេះគឺជាមូលដ្ឋានក្នុងការសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ យ៉ាងណាក៏ដោយ ក៏ពួកគាត់កត់សម្គាល់ថា ដោយអនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ពួកគាត់បានកាត់បន្ថយយ៉ាងច្រើននូវចំនួន (និងចំនួនសរុបនៃទំព័រ) នៃកំណត់ហេតុ

---

[61] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន អនុលោមតាមវិធាន ៩២ កថាខណ្ឌ ៣៥។

[62] សេចក្តីសម្រេចទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៤(ខ) (ដែលបង្ហាញថា កត្តាដែលគាំទ្រដល់ការទទួលយកភ័ស្តុតាង និងការផ្តល់នូវតម្លៃជាភ័ស្តុតាងមួយចំនួនចំពោះកំណត់ហេតុស្តាប់ចម្លើយគឺថា វាមានភ័ស្តុតាងដែលបង្ហាញអំពីកម្រិតធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ")។

[63] ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ៤៩។

[64] ការជំទាស់ចុងក្រោយរបស់ នួន ជា ERN 00902860 (ចាប់ពីដើមដល់កថាខណ្ឌ ១៥) និងកថាខណ្ឌ ៣៣។

[65] ដូចខាងលើ ត្រង់កថាខណ្ឌ ១០។

ស្ដាប់ចម្លើយដែលពួកគាត់ស្នើសុំឱ្យទទួលយកជាភ័ស្តុតាង[66]។ ដូចដែលបានកត់សម្គាល់ពីមុន តារាងថ្ងៃទី ៤ ខែ មីនា របស់ដើមបណ្ដឹងរដ្ឋប្បវេណី រួមមានឯកសារពិសេសចំនួន ៥២០[67] ដែលចំនួនទំព័រ ឬសម្រង់ដែលពាក់ព័ន្ធនៃឯកសារទាំងនោះ ភាគច្រើន មិនលើសពី ១-៣ ទំព័រឡើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានផ្ដល់ព័ត៌មានលម្អិតផងដែរស្ដីអំពីចំណុចនៃការចោទប្រកាន់ និងគោលបំណងនៃភ័ស្តុតាងនៃឯកសារនីមួយៗ ដែលមាននៅក្នុងតារាងថ្ងៃទី ៤ ខែ មីនា របស់ពួកគាត់ ដូច្នេះអាចផ្ដល់ឱ្យមេធាវីការពារក្ដី និងអង្គជំនុំជម្រះសាលាដំបូងនូវព័ត៌មានចាំបាច់ ដើម្បីអាចវាយតម្លៃលើឯកសារទាំងនេះប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត ចំនួនសរុបនៃឯកសារដែលបានស្នើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី តំណាងឱ្យតែ ៥០% ប៉ុណ្ណោះនៃឯកសារដែលបានស្នើឡើងដោយព្រះរាជអាជ្ញា[68]។ ដូច្នេះ ចំនួនកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺសមហេតុផល ដោយធៀបទៅនឹងចំនួនឯកសាររបស់ព្រះរាជអាជ្ញា និងដោយពិចារណាទៅលើវិសាលភាព និងភាពស្មុគស្មាញនៃកិច្ចដំណើរការនីតិវិធី។

## *ឈ. ដើមបណ្ដឹងរដ្ឋប្បវេណីបានចង្អុលបង្ហាញ និងបានសម្របសម្រួលយ៉ាងល្អក្នុងការបកប្រែកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលពួកគាត់បានស្នើសុំឱ្យទទួលយកជាភ័ស្តុតាង*

40. មេធាវីការពារក្ដី ខៀវ សំផន អះអាងថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែ "ចង្អុលបង្ហាញឱ្យបានច្បាស់ [...] នូវផ្នែកណាខ្លះនៃកំណត់ហេតុស្ដាប់ចម្លើយ ដែលខ្លួនមានបំណងប្រើប្រាស់"[69]។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដីពុំបានដកស្រង់ប្រភពគាំទ្រណាមួយ ដើម្បីអះអាងបញ្ជាក់អំពីជំហរនេះឡើយ។ ដូចដែលបានកត់សម្គាល់ពីមុន ក្នុងការឆ្លើយតបទៅនឹងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់ព័ត៌មានយ៉ាងច្រើនជូនក្រុមមេធាវីការពារក្ដី ដើម្បីជួយពួកគាត់ក្នុងការវាយតម្លៃអំពីកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំង

---

[66] ដូចខាងលើ ត្រង់កំណត់សម្គាល់ ៩។

[67] ដូចខាងលើ ត្រង់កថាខណ្ឌ ៦ និងកំណត់សម្គាល់ ៧។

[68] សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោមតាមវិធាន ៨០(៣) (កំណត់ហេតុស្ដាប់ចម្លើយសាក្សី និងពាក្យបណ្ដឹង) ឯកសារ **E278** កថាខណ្ឌ ២ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ (ដែលដកស្រង់ចំនួនសរុបនៃឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធទី ១២ និងទី១៣ ដែលបានកែសម្រួលឡើងវិញរបស់ព្រះរាជអាជ្ញា ចំនួន ១០៤០)។

[69] ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ៤៥។

សេចក្ដីបញ្ជាក់លម្អិតទៅលើគោលបំណងជាភ័ស្ដុតាងនៃឯកសារ (ដែលពិពណ៌នាខ្លឹមសារដែលពាក់ព័ន្ធ) និងការដកស្រង់នូវចំណុចដែលពាក់ព័ន្ធនៃការចោទប្រកាន់។ ដោយពិចារណាលើចំណុចនេះ និងអង្គហេតុដែលថាអង្គជំនុំជម្រះសាលាដំបូងពុំដែលបានបញ្ជាក់អំពីលក្ខខណ្ឌតម្រូវណាមួយ ហួសពីអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់ជូន ដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា ពួកគាត់បានចង្អុលបង្ហាញភ័ស្ដុតាងយ៉ាងត្រឹមត្រូវដែលពួកគាត់នឹងយកមកធ្វើជាសំអាងនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីដែលពួកគាត់បានផ្ដល់ជូននោះ។

41. លើសពីនេះទៀត មេធាវីការពារក្ដី ខៀវ សំផន អះអាងថា "'ការបកប្រែ' នៃកំណត់ហេតុស្ដាប់ចម្លើយទាំងនេះជាភាសាអង់គ្លេស និងបារាំង ភាគច្រើនជាសេចក្ដីសង្ខេបប៉ុណ្ណោះ ដែលភាពអាចជឿទុកចិត្តបាននៃសេចក្ដីសង្ខេបទាំងនោះ ត្រូវបានជំទាស់តវ៉ាខ្លាំងជាងច្បាប់ដើមទៅទៀត"[70]។

42. បន្ទាប់ពីបានពិនិត្យឡើងវិញនូវតារាងរបស់ពួកគាត់ ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា ឯកសារចំនួន ៤៦ ឬ ៨% នៃឯកសារចំនួន ៥៦៦ ដែលមាននៅក្នុងបញ្ជីថ្ងៃទី ៤ ខែ មីនា របស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺពិតណាស់ជាឯកសារសេចក្ដីសង្ខេប ដែលត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីនេះដោយភ័ន្តច្រឡំ។ ទោះបីជាយ៉ាងណាក៏ដោយ ដើមបណ្ដឹងរដ្ឋប្បវេណីសង្កត់ធ្ងន់ថា ទម្រង់ព័ត៌មានជនរងគ្រោះដើមទាំងអស់សម្រាប់ឯកសារសង្ខេបទាំង ៤៦ នេះ ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីថ្ងៃទី ៤ ខែ មីនា របស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដូចដែលបានរំពឹងទុក ទម្រង់ព័ត៌មានជនរងគ្រោះដើមទាំងអស់ត្រូវបានបកប្រែ ឬនឹងត្រូវបានបកប្រែជាភាសាមួយក្នុងចំណោមភាសាផ្លូវការបីរបស់តុលាការ នៅត្រឹមពេលបញ្ចប់សវនាការលើអង្គសេចក្ដីលើសំណុំរឿង ០០២/០១[71]។

43. ដើម្បីធានាថា គ្រប់ភាគី និងអង្គជំនុំជម្រះមានភាពងាយស្រួលក្នុងការចង្អុលបង្ហាញថាកំណត់ហេតុស្ដាប់ចម្លើយសាក្សីណាខ្លះ ត្រូវបានដាក់ចូលក្នុងបញ្ជីដោយភ័ន្តច្រឡំនោះ ដើមបណ្ដឹងរដ្ឋប្បវេណីសូមភ្ជាប់ជាមួយសារណានេះនូវបញ្ជីឯកសារទាំងនេះជាឧបសម្ព័ន្ធ[72]។ លើសពីនេះទៀត ដើម

[70] ដូចយោងខាងលើ កថាខណ្ឌ ៥៤។

[71] សារណាថ្ងៃទី ៤ ខែ មីនា កថាខណ្ឌ ១៤។

[72] សូមមើល ឧបសម្ព័ន្ធ ១៖ បញ្ជីសេចក្ដីសង្ខេបកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដែលដាក់បញ្ចូលទៅក្នុងគំរូដែលជាតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដោយភ័ន្តច្រឡំ (ឯកសារ E223/2/7.2) (ភ្ជាប់មកជាមួយ)។

បណ្ដឹងរដ្ឋប្បវេណីនឹងដាក់សំណើសុំកែតម្រូវចំពោះតារាងថ្ងៃទី ៤ ខែ មីនា ដែលនឹងលុបចេញនូវកំណត់ហេតុស្ដាប់ចម្លើយទាំងនេះ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## IV. **សេចក្ដីសន្និដ្ឋាន**

44. **ដោយផ្អែកលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ** ដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ទទួលយកសារណាតបនេះ

ខ. បដិសេធការជំទាស់របស់ក្រុមមេធាវី ខៀវ សំផន និង នួន ជា ទាំងស្រុង និង

គ. ទទួលយកជាភស្ដុតាងនូវកំណត់ហេតុស្ដាប់ចម្លើយទាំងអស់ដែលបានដាក់ជូនជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ និងដែលបានរៀបរាប់នៅក្នុងតារាងថ្ងៃទី ៤ ខែ មីនា របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ដូចដែលបានកែតម្រូវដើម្បីលុបចេញឯកសារសង្ខេបចំនួន ៤៦ ដែលបានដាក់ចូលដោយភ័ន្ដច្រឡំ)។

ដាក់ជូនដោយសេចក្ដីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខ | ភ្នំពេញ | |